ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខៈ ............................/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី.០២ ខែមករា.. ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីកិច្ចប្រជុំលើកទី១៣របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់សាធារណៈជន និងបណ្តាញសារព័ត៌មានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា គ.ជ.អ.ប នឹងរៀបចំកិច្ចប្រជុំលើកទី១៣ របស់ខ្លួន នាថ្ងៃ **ទី០៤ ខែមករា ឆ្នាំ២០១៧ ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១២:៣០ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ (អគារA)**។

កិច្ចប្រជុំនេះនឹងប្រារព្ធទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប** ដោយមានការអញ្ជើញចូលរួមពីរដ្ឋមន្ត្រីសមាជិកគ.ជ.អ.ប តំណាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

កិច្ចប្រជុំនេះ មានរបៀបវារៈដូចខាងក្រោម៖

១.ការអនុម័តលើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំ គ.ជ.អ.ប លើកទី១២

២.ពិភាក្សា និងអនុម័តលើសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧របស់គ.ជ.អ.ប

៣.ពិភាក្សា និងអនុម័តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៤.ពិភាក្សា និងអនុម័តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៥.ពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៦.ពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៧.ពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងបញ្ជីមុខងារក្នុងវិស័យអាទិភាពនានាដែលត្រូវស្នើផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

៨.ពិនិត្យ និងអនុម័តលើឯកសារបំពេញបន្ថែមចំពោះកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

៩.បញ្ហាផ្សេងៗ៖

- របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃអំពីស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងវិស័យជំនាញនានានៅថ្នាក់ក្រុង ស្រុកនាពេលបច្ចុប្បន្ន។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងអ្នកសារព័ត៌មាន សូមអញ្ជើញចូលរួមយកព័ត៌មាន។

*សូមទំនាក់ទំនងមកលេខាធិការដ្ឋាន គ.ជ.អ.ប ជាមុនតាមរយៈ*

*លេខទូរស័ព្ទ: 077 785 445 / 078 575 775*

*Email: tharith@ncdd.gov.kh*

*Website: www.ncdd.gov.kh*